**ព្រះរាជាណាចក្រកម្ពុជា**
ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងអភិវឌ្ឍន៍ជនបទ**
លេខៈ ១១៤៦/២៣ ក.អ.ជ

ថ្ងៃពុធ ៤កើត ខែបឋមាសាឍ ឆ្នាំថោះ បញ្ចស័ក ព.ស. ២៥៦៧
រាជធានីភ្នំពេញ ថ្ងៃទី ២១ ខែ មិថុនា ឆ្នាំ ២០២៣

# របាយការណ៍
# វឌ្ឍនភាពការងារប្រចាំខែឧសភា និងទិសដៅការងារខែមិថុនា ឆ្នាំ២០២៣
# របស់ក្រសួងអភិវឌ្ឍន៍ជនបទ

## ១. សេចក្ដីផ្ដើម

ខែឧសភា ឆ្នាំ២០២៣នេះ រាជរដ្ឋាភិបាលកម្ពុជា បានសម្រេចនូវស្នាដៃជាប្រវត្តិសាស្ត្រមួយទៀត ដោយបានធ្វើជាម្ចាស់ផ្ទះព្រឹត្តិការណ៍ប្រកួតកីឡាអាស៊ីអាគ្នេយ៍លើកទី៣២ ប្រកបដោយជោគជ័យ។ ក្រសួងអភិវឌ្ឍន៍ជនបទ បាននិងកំពុងការអនុវត្តផែនការសកម្មភាពដែលមានក្នុងផែនការឆ្នាំ២០២៣ កំពុងដំណើរការដោយរលូន ។ ក្រសួងបាន និងកំពុងពន្លឿនការងារសាងសង់ហេដ្ឋារចនាសម្ព័ន្ធជនបទ ឱ្យបានលឿនតាមដែលអាចធ្វើទៅបានមុននឹងរដូវវស្សាឈានចូលមកដល់។

លទ្ធផលសម្រេចបានក្នុងខែឧសភា ឆ្នាំ២០២៣ នេះមានដូចខាងក្រោមៈ

## ២. វឌ្ឍនភាពការងារ

### ២.១. លទ្ធផលរួមរបស់ក្រសួងអភិវឌ្ឍន៍ជនបទ

ការអនុវត្តផែនការថវិកាតាមកម្មវិធីក្នុងខែឧសភានេះនៅទូទាំងប្រទេសសម្រេចបានប្រមាណ ២៦,០៩% នៃថវិកាកម្មវិធីប្រចាំឆ្នាំ២០២៣ ។

### ២.២. លទ្ធផលរបស់អង្គភាពចំណុះក្រសួងអភិវឌ្ឍន៍ជនបទ

#### ២.២.១. ការងាររដ្ឋបាល និងបុគ្គលិក

ដោយគិតត្រឹមដំណាច់ខែឧសភា ឆ្នាំ ២០២៣ មន្ត្រីរាជការក្របខណ្ឌសរុបមានចំនួន ១ ៤៧៦ នាក់ (ស្រីចំនួន ៤០៣ នាក់) ។ ក្រសួងបានទទួលលិខិតចូលចំនួន ២១២ច្បាប់ និងបានរៀបចំលិខិតបទដ្ឋានរដ្ឋបាល និងបទដ្ឋានគតិយុត្តពាក់ព័ន្ធ និងវឌ្ឍនភាពការងាររបស់ក្រសួង បានចំនួន ៤៩២ លិខិត ។

#### ២.២.២.ការងារផ្គត់ផ្គង់ និងហិរញ្ញវត្ថុ

ក្នុងខែឧសភា នេះក្រសួងបានអនុវត្តចំណាយធៀបនឹងច្បាប់ហិរញ្ញវត្ថុសម្រាប់ឆ្នាំ ២០២៣ សម្រេចបាន ៖

- ចំណាយចរន្តអនុវត្តបានចំនួន ៨ ៣៣៣,៧២ លានរៀលស្មើនឹង ១,៦៦% នៃច្បាប់ថវិកា
- ចំណាយមូលធនអនុវត្តបានចំនួន ១០១ ៤៥៥,៦៤ លានរៀលស្មើនឹង ២៤,៤៣% នៃច្បាប់ថវិកា។



អាសយដ្ឋានៈ ដីឡូត៍លេខ ៧៧១-៧៧៣ មហាវិថីព្រះមុនីវង្ស សង្កាត់បឹងត្របែក ខណ្ឌចំការមន រាជធានីភ្នំពេញ
ទូរស័ព្ទ (855) 23 884 639 គេហទំព័រ www.mrd.gov.kh អ៊ីមែល dap.mrd@gmail.com

### ២.២.៣. ការងារកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ

- អនុវត្តផែនការសកម្មភាពដំណាក់កាលទី៤ ឆ្នាំ២០២៣ (MAP4)
- បំពេញកម្រងសំណួរ (Survey) ស្ទាបស្ទង់ការបណ្តុះបណ្តាលរយៈពេលខ្លី
- រៀបចំសេចក្តីព្រាងស្តីពីគោលការណ៍ណែនាំការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈក្រសួង
- ពិនិត្យលើសេចក្តីព្រាងក្របខណ្ឌវាយតម្លៃប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

### ២.២.៤. ក្រុមការងារបច្ចេកទេសវិមជ្ឈការ និងវិសហមជ្ឈការ

(គ្មានសកម្មភាព)

### ២.២.៥. ការងារផែនការ និងសហប្រតិបត្តិការអន្តរជាតិ

- បានផ្តល់ធាតុចូលសម្រាប់រៀបចំផែនការ យុទ្ធសាស្រ្តអភិវឌ្ឍន៍ជាតិ (ផ.យ.អ.ជ) ឆ្នាំ២០២៤-២០២៨ ផ្នែកក្រសួងអភិវឌ្ឍន៍ជនបទ ជូនក្រសួងផែនការ
- បានរៀបចំសិក្ខាសាលា ស្តីពីការរៀបចំសេចក្តីព្រាងបឋមសៀវភៅគោលការណ៍ណែនាំ ស្តីពីការអនុវត្ត និងគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (FMM) របស់ក្រសួងអភិវឌ្ឍន៍ជនបទ ដោយសហការជាមួយក្រុមការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ នៃក្រសួងអភិវឌ្ឍន៍ជនបទ (PFM-MRD)
- បានចុះណែនាំពីការធ្វើអង្កេតទិន្នន័យ និងប្រមូលទិន្នន័យអភិវឌ្ឍន៍ជនបទនៅខេត្តក្រចេះ និងខេត្តបន្ទាយមានជ័យ
- ចុះតាមដាន និងត្រួតពិនិត្យ សកម្មភាពការងារប្រចាំឆ្នាំ២០២៣ របស់ខេត្តស្ទឹងត្រែង
- បានរៀបចំបន្តកិច្ចព្រមព្រៀងសហប្រតិបត្តិការរវាងក្រសួងអភិវឌ្ឍន៍ជនបទ ជាមួយអង្គការចំនួន០៤ រួមមាន៖ អង្គការអាគ្រីស៊ុតកម្ពុជា អង្គការអាយឌីអ៊ី អង្គការ DPA និងអង្គការទឹកស្អាត១០០១
- បានផ្តល់លិខិតគាំទ្រ ដើម្បីបន្តអនុស្សរណៈនៃការយោគយល់គ្នារវាង អង្គការWaterAid ជាមួយក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ
- ធ្វើបច្ចុប្បន្នភាពប្រព័ន្ធគ្រប់គ្រងមូលដ្ឋានទិន្នន័យផ្លូវជនបទប្រព័ន្ធគ្រប់គ្រងទិន្នន័យមន្ត្រីរាជការ និងគេហទំព័រក្រសួងអភិវឌ្ឍន៍ជនបទ ។

### ២.២.៦. ការងារអធិការកិច្ច និងសវនកម្ម

- បានចុះធ្វើសវនកម្មលើថវិកាកម្មវិធីបានចំនួន០៥ខេត្ត គឺខេត្តកំពង់ចាម ខេត្តត្បូងឃ្មុំ ខេត្តក្រចេះ ខេត្តកោះកុង និងខេត្តកំពង់ឆ្នាំង និងធ្វើសវនកម្មលើគម្រោងពិពិធកម្មវិស័យកសិកម្មកម្ពុជា
- ចុះធ្វើអធិការកិច្ចលើការងារគ្រប់គ្រងចំណូល-ចំណាយ និងការប្រើប្រាស់ថវិការបស់រដ្ឋការិយបរិច្ឆេទ២០២២ នៅមន្ទីរអភិវឌ្ឍន៍ជនបទ បានចំនួន ០៦ ខេត្ត រួមមាន ខេត្តកំពង់ចាម ខេត្តត្បូងឃ្មុំ ខេត្តក្រចេះ ខេត្តកំពង់ឆ្នាំង ខេត្តស្ទឹងត្រែង និងខេត្តរតនៈគិរី ។

### ២.២.៧. ការងារអភិវឌ្ឍន៍ផ្លូវជនបទ និងមន្ទីរពិសោធន៍

- ការងារថែទាំខួប ឆ្នាំ ២០២៣ កំពុងដំណើរការសៀវភៅបញ្ជីប៉ាន់តម្លៃ និងគ្រោងប្លង់ សម្រេចលទ្ធផលគិតជាមធ្យមបាន ១០០% នៃគម្រោងសរុប ៣០គម្រោង រួមមាន ផ្លូវក្រាលក្រួសក្រហម ចំនួន ២៦ គម្រោង ស្មើនឹង ៥០ខ្សែ ប្រវែងសរុប ៣២៥,៥៣ គ.ម លូមូល ៤៨ កន្លែង និងលូប្រអប់ ០២ កន្លែង និងផ្លូវក្រាលកៅស៊ូ DBST ចំនួន ០៤ គម្រោង ស្មើនឹង ០៦ខ្សែ ប្រវែងសរុប ២៧,៨៥ គ.ម
- ការងារថែទាំប្រចាំ ឆ្នាំ ២០២៣ កំពុងដំណើរការសៀវភៅបញ្ជីប៉ាន់តម្លៃ និងគ្រោងប្លង់ សម្រេចលទ្ធផលគិតជាមធ្យមបាន ១០០% នៃគម្រោងសរុប ៣៤ គម្រោង រួមមាន ផ្លូវក្រាលក្រួសក្រហម ចំនួន ២៤ គម្រោង ស្មើនឹង ២៦៧ខ្សែ ប្រវែងសរុប ២ ៥០៥,២៧ គ.ម ផ្លូវក្រាលកៅស៊ូ DBST ចំនួន ១០ គម្រោង ស្មើនឹង ៧៨ខ្សែ ប្រវែងសរុប ១ ១៦៦,៣៦ គ.ម លូមូល ០២ កន្លែង និងស្លាកសញ្ញាចរាចរចំនួន ១ ៧៦២ស្លាក
- ការងារស្ដាបនា កែលម្អ និងជួសជុល ឆ្នាំ២០២២ គម្រោងជំហានទី១ចំនួន ២៩ គម្រោង និងជំហានទី២ចំនួន ៤០គម្រោង សរុបប្រវែង ២៥៦.៦៥ គ.ម សម្រេចលទ្ធផលគិតជាមធ្យមបាន ៩៥,៤០ %
- ការងារស្ដាបនា កែលម្អ និងជួសជុល ឆ្នាំ២០២៣ សរុបចំនួន ៨៦ គម្រោង សរុបប្រវែង ៣៨២.៣៨ គ.ម សម្រេចលទ្ធផលគិតជាមធ្យមបាន ៤៣,៥៤ %
- បានចុះត្រួតពិនិត្យ និងវាយតម្លៃ ចំនួន ១០២ គម្រោង ក្នុងនោះគម្រោងជំពូក ២១ ចំនួន ២៩ គម្រោង និងគម្រោងជំពូក ៦១ ចំនួន ៧៣ គម្រោង
- ទទួលសំណាកគំរូបានចំនួន ១៨ សំណាករណ្ដៅ
- ធ្វើពិសោធន៍បានរួចរាល់១០០% បានចំនួន ១៨ សំណាករណ្ដៅ។

### ២.២.៨. ការងារផ្គត់ផ្គង់ទឹកជនបទ

- បានចុះសិក្សាទីតាំងសាងសង់ និងជួសជុលប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាតជនបទ នៅខេត្តស្ទឹងត្រែង
- បានចុះអប់រំផ្សព្វផ្សាយ ស្ដីពីការប្រើប្រាស់ ការផឹកទឹកស្អាតប្រកបដោយសុវត្ថិភាពតាមខ្នងផ្ទះ នៅភូមិលែង ឃុំទំរីង ស្រុកសណ្ដាន់ មានអ្នកចូលរួម ចំនួន ២១ គ្រួសារ ស្មើនឹង ៨០ នាក់ (ស្រី ៥២ នាក់ និងកុមារ ២៨ នាក់)
- បានសាសង់អណ្ដូងស្នប់អាហ្វ្រីដេវ ចំនួន ១៣ អណ្ដូង នៅខេត្តកំពង់ចាម ខេត្តពោធិ៍សាត់ ខេត្តត្បូងឃ្មុំ និងខេត្តប៉ៃលិន
- បានជួសជុលអណ្ដូងស្នប់អាហ្វ្រីដេវ ចំនួន ០១ អណ្ដូង នៅភូមិកាណង ឃុំតាឡាវ ស្រុកអណ្ដូងមាស ខេត្តរតនគិរី ។

### ២.២.៩. ការងារថែទាំសុខភាព និងអនាម័យជនបទ

- ដឹកនាំប្រជុំមន្ត្រីបច្ចេកទេសស្ដីពីអនាម័យស្ត្រី និងកុមារពេលមានរដូវ មានការចូលរួមពីតំណាង Unicef និងក្រុមការងារខេត្តគោលដៅ

សូចនាករទឹកស្អាត និងអនាម័យដើម្បីឆ្លើយតបគោលដៅអភិវឌ្ឍប្រកបដោយចីរភាព
- ចូលរួមសិក្ខាសាលាស្តីពីការរៀបចំទស្សនទានអាកាសធាតុសម្រាប់សេវាទឹកស្អាត និងអនាម័យនៅកម្ពុជា ។

**២.២.១០. ការងារអភិវឌ្ឍន៍សហគមន៍**

- ចុះពិនិត្យស្ថានភាពការងារអភិវឌ្ឍន៍សហគមន៍ នៅខេត្តក្រចេះ ខេត្តត្បូងឃ្មុំ និងខេត្តស្ទឹងត្រែង
- មជ្ឈមណ្ឌលអភិវឌ្ឍន៍ជនបទខេត្តតាកែវ បានធ្វើការផ្សព្វផ្សាយវគ្គបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈ ក្រោមមជ្ឈមណ្ឌល ចំនួន ១០ វគ្គ មានសិក្ខាកាមចំនួន ២០០ នាក់
- មជ្ឈមណ្ឌលអភិវឌ្ឍន៍ជនបទខេត្តកំពង់ស្ពឺ បានជូនដំណឹង ស្តីពីការជ្រើសរើសសិក្ខាកាមសម្រាប់បើកវគ្គបណ្តុះបណ្តាលជំនាញបច្ចេកទេសមិនទាន់គ្រប់ចំនួន០៧វគ្គមានសិក្ខាកាមចំនួន ៥៤ នាក់ ខ្វះ ៨៦ នាក់ ។

**២.២.១១. ការងារបណ្តុះបណ្តាល**

- មន្ត្រីចូលរួមវគ្គបណ្តុះបណ្តាលក្នុងប្រទេស ចំនួន ៩៧នាក់ ក្នុងនោះស្រី ៣០នាក់
- មន្ត្រីចូលរួមវគ្គបណ្តុះបណ្តាលក្រៅប្រទេស ចំនួន ០១នាក់
- មន្ត្រីចូលរួមវគ្គសិក្ខាសាលាក្នុងប្រទេស ចំនួន ១៩១នាក់ ក្នុងនោះស្រី ៤២នាក់
- បានរៀបចំលិខិតចាត់បញ្ជូនមន្ត្រីរាជការចំនួន ០២ រូប ឱ្យទៅចូលរួមវគ្គបណ្តុះបណ្តាល
- មជ្ឈមណ្ឌលបណ្តុះបណ្តាលជំនាញមូលដ្ឋានទាំង ១១ ខេត្ត រួមមាន ៖ ខេត្តព្រៃវែង ខេត្តស្វាយរៀង ខេត្តកំពង់ចាម ខេត្តបាត់ដំបង ខេត្តពោធិ៍សាត់ ខេត្តកំពត ខេត្តកំពង់ធំ ខេត្តបន្ទាយមានជ័យ ខេត្តសៀមរាប ខេត្តកំពង់ឆ្នាំង និងខេត្តកណ្តាល បានបើកវគ្គបណ្តុះបណ្តាលមុខជំនាញវិជ្ជាជីវៈរយៈពេលវែង និងរយៈពេលខ្លីចំនួន ១២វគ្គ មានសិក្ខាកាមចំនួន ១៩៩នាក់ ស្រី ៧៣នាក់ ។

**២.២.១២. ការងារអភិវឌ្ឍន៍សេដ្ឋកិច្ចជនបទ**

- គិតត្រឹមថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០២៣ ប្រតិបត្តិករឥណទានជនបទដែលមន្ទីរអភិវឌ្ឍន៍ជនបទខេត្តកំពុងអនុវត្តផ្ទាល់ សហការជាមួយដៃគូ និងសកម្មភាពការងារឥណទានដែលអនុវត្តដោយសហគមន៍សន្សំប្រាក់ បានផ្តល់ឥណទាន សរុបចំនួន ៤ ១៧៣ ០១៧ ៧៧៥ រៀល (បួនប៊ីលានមួយរយចិតសិបបីលានដប់ប្រាំពីរពាន់ប្រាំពីររយចិតសិបប្រាំរៀល) ស្មើនឹង ១ ០៤៣ ២៥៤,៤៤ ដុល្លារអាមេរិក (មួយលានសែសិបបីពាន់ពីររយហាសិបបួនដុល្លារ និងសែសិបបួនសេន) (១USD=៤០០០ រៀល) មានអ្នកខ្ចីសរុបចំនួន ៣ ៥៦១ នាក់ ស្រីចំនួន ២៩៥៥ នាក់ នៅភូមិគោលដៅចំនួន ១៧០ ភូមិ ៦៨ ឃុំ ៣១ ស្រុក ក្នុងខេត្តគោលដៅចំនួន ១៥ ។

**២.២.១៣. ការងារគ្រប់គ្រង និងអភិវឌ្ឍន៍ជនជាតិដើមភាគតិច**

- រៀបចំសិក្ខាសាលា ស្តីពីការអនុវត្តផែនការថវិកាឆ្នាំ ២០២៣ និងការបន្ស៊ីថវិកាឆ្នាំ២០២៤ រវាងនាយកដ្ឋានអភិវឌ្ឍន៍ជនជាតិភាគតិច និងមន្ទីរអភិវឌ្ឍន៍ជនបទទាំង១៥ខេត្ត

- រៀបចំកិច្ចប្រជុំ ស្តីពីការកំណត់អត្តសញ្ញាណសហគមន៍ជនជាតិដើមភាគតិចកួយ នៅភូមិបឹងចារ ឃុំបឹងចារ ស្រុកសំបូរ ខេត្តក្រចេះ ជាលទ្ធផលសមាជិកសហគមន៍បានការឯកភាពស្រុះស្រួលឆន្ទៈគ្នា ក្នុងការស្នើសុំទទួលស្គាល់អត្តសញ្ញាណ សហគមន៍ជនជាតិដើមភាគតិចកួយ ។

**២.២.១៤.ក្រុមការងារចុះមូលដ្ឋានតាមដានការអនុវត្តយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤**

ក្នុងខែឧសភា ឆ្នាំ ២០២៣ នេះ លេខាធិការដ្ឋានក្រុមការងារចុះមូលដ្ឋានរបស់ក្រសួងអភិវឌ្ឍន៍ជនបទបានទទួលសំណើ សំណូមពរប្រជាពលរដ្ឋចំនួន ០២ករណី ។

**២.២.១៥. ការងារយេនឌ័រ**

(គ្មានសកម្មភាព)

**២.២.១៦. ការងារប្រយុទ្ធនឹងជំងឺអេដស៍**

(គ្មានសកម្មភាព)

**២.៣. ការអនុវត្តគម្រោង និងកម្មវិធីសហប្រតិបត្តិការទ្វេភាគី និងពហុភាគី**

**២.៣.១.គម្រោងសាច់ប្រាក់ពលកម្មសម្រាប់អភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធជនបទនិងការគាំទ្រកសិករ**

ការងារក្រាលស្រទាប់ដីក្រហម ឬល្បាយថ្មក្ំឆ្នាំ២០២៣ សម្រាប់ខែឧសភា ឆ្នាំ២០២៣នេះ គម្រោងអនុវត្តសម្រេចបានចំនួន ៤៦អនុគម្រោង ប្រវែង ១៤៤ ១១៤ ម៉ែត្រ នៃអនុគម្រោងសរុបចំនួន ៣០១អនុគម្រោង ប្រវែង ៩១១ ៣៨១ ម៉ែត្រ ស្មើនឹង ១៦ ភាគរយ នៃអនុគម្រោងដែលបានអនុម័តក្នុងឆ្នាំ២០២៣ ។

**២.៣.២.គម្រោងកិច្ចសហប្រតិបត្តិការមេគង្គឡានឆាង** (Mekong Lancang Cooperation)

- គម្រោងបំពេញបន្ថែមលើគម្រោងសហប្រតិបត្តិការកាត់បន្ថយភាពក្រីក្រកម្ពុជា-ចិន
  - បានចុះទៅជួបពិភាក្សាជាមួយអាជ្ញាធរឃុំ អំពីការចុះធ្វើកិច្ចសម្ភាសន៍របស់ភាគីចិន
  - បានចូលរួមក្នុងវគ្គបណ្តុះបណ្តាលបច្ចេកទេសបណ្តុះផ្សិតដល់គណៈកម្មការសហគមន៍ផលិតផ្សិតនៅភូមិស្វាយអំពារ ឃុំស្វាយអំពារ ស្រុកមុខកំពូល ខេត្តកណ្តាល
- គម្រោងចែកចាយទឹកស្អាត ដើម្បីអនាគតទាំងអស់គ្នា
  - បានដឹកនាំប្រជាជនចំនួន ១០០នាក់ មកពីសហគមន៍ចំនួន៤ នៃស្រុកគិរីវង់ ខេត្តតាកែវ ដើម្បីធ្វើដំណើរចុះទស្សនកិច្ចសិក្សា ទៅកាន់ខេត្តសៀមរាប
  - បានចុះពិនិត្យ និងតាមដានការតបណ្តាញទឹកស្អាតរបស់សហគមន៍ទាំង ០៤ ដោយបានជីក និងបង្កប់ទុយោ បានសរុបចំនួន ២៧ ៥២០ ម៉ែត្រ
  - បានរៀបចំពិធីប្រគល់-ទទួល កុំព្យូទ័រ និងព្រីនធ័រ ជូនសហគមន៍ ទាំងបួន ស្ថិតនៅឃុំតាអូរ ស្រុកគិរីវង់ ខេត្តតាកែវ
- គម្រោងពិពិធកម្មសេដ្ឋកិច្ចជនបទ សម្រាប់កសិករដែលមានចំណូលទាប
  - បានរៀបចំវគ្គបណ្តុះបណ្តាលស្តីពី "ការផ្លាស់ប្តូរផ្នត់គំនិត ដើម្បីបង្កើនប្រាក់ចំណូល" ចំនួន ០៦វគ្គ

- រៀបចំវគ្គបណ្តុះបណ្តាលធ្វើសិប្បកម្មសាប៊ូ ដល់សមាជិកសហគមន៍កសិកម្ម ស្ថិតក្នុងស្រុកគិរីវង់ ខេត្តតាកែវ
- បានរៀបចំពិធីប្រគល់-ទទួល ឃ្លាំងស្តុកបន្លែ និងជង្រុកស្រូវ ជូនសហគមន៍ទាំងបួនស្ថិតនៅឃុំតាអូរ ស្រុកគិរីវង់ ខេត្តតាកែវ ។

### ២.៣.៣. គម្រោងសហប្រតិបត្តិការមេគង្គ-គង្គា

- បានចុះត្រួតពិនិត្យការងារ និងសមិទ្ធផលគម្រោងនៅខេត្តកំពង់ឆ្នាំង ខេត្តពោធិ៍សាត់ និងខេត្តបាត់ដំបង ជាមួយស្ថានទូតឥណ្ឌាប្រចាំកម្ពុជា ។

### ២.៣.៤. គម្រោងគ្រប់គ្រងគ្រោះមហន្តរាយនៅកម្ពុជា និងអាស៊ីអាគ្នេយ៍ ដំណាក់២

គម្រោងគ្រប់គ្រងគ្រោះមហន្តរាយនៅកម្ពុជា និងអាស៊ីអាគ្នេយ៍ ដំហាន២ ប្រើប្រាស់ថវិកាហិរញ្ញប្បទានឥណទានសហប្រតិបត្តិការ ពីធនាគារពិភពលោក គ្រោងស្ថាបនាផ្លូវក្រាលកៅស៊ូពីរជាន់ ប្រភេទ DBST និងប្រភេទផ្លូវបេតុងចំពោះតំបន់មានទឹកលិច ប្រវែងសរុបចំនួន ៧៧៧គីឡូម៉ែត្រ ព្រមទាំងសំណង់សិល្បការ្យជាច្រើនទៀត នៅខេត្តគោលដៅចំនួន ០៨រួមមាន ខេត្តត្បូងឃ្មុំ ខេត្តកំពង់ចាម ខេត្តកំពង់ឆ្នាំង ខេត្តកំពង់ស្ពឺ ខេត្តពោធិ៍សាត់ ខេត្តបាត់ដំបង ខេត្តបន្ទាយមានជ័យ និងខេត្តសៀមរាប ។ គិតត្រឹមខែឧសភានេះ គម្រោងសម្រេចបាន ៖

- បានបញ្ចប់ការងារលទ្ធកម្ម និងចាប់ផ្តើមការងារសាងសង់ កាលពីក្នុងខែ មីនា ឆ្នាំ ២០២៣ សម្រាប់កញ្ចប់ទី១
- បានបញ្ចប់ការងារសិក្សាផ្លូវ និងបានធ្វើរចនាប្លង់លំអិត សម្រាប់កញ្ចប់ទី២
- បាន និងកំពុងរៀបចំលក្ខខណ្ឌការងារ សម្រាប់ការជ្រើសរើសក្រុមហ៊ុនទីប្រឹក្សា Design and Supervision Firm សម្រាប់ការងាររចនាប្លង់កញ្ចប់ដែលនៅសេសសល់ និងការងារត្រួតពិនិត្យគុណភាពផ្លូវ ។

### ២.៣.៥. គម្រោងផ្គត់ផ្គង់ទឹកជនបទ និងកែលម្អផ្លូវជនបទ ក្រោមហិរញ្ញប្បទានឥតសំណងរបស់រដ្ឋាភិបាល នៃសាធារណរដ្ឋប្រជាមានិតចិន ដំហាន ២

- បានជីកអណ្តូងបានចំនួន ៩៦៤ តម្លើងស្នប់បានចំនួន ៩៦៤ ជីកស្រះធម្មតាបានចំនួន ១២ និងស្រះមានរៀបថ្មបានចំនួន ៤២ សម្រេចលទ្ធផលស្មើនឹងចំនួន ១០០%
- ការស្ថាបនាផ្លូវជនបទក្រាលកៅស៊ូប្រវែងសរុប ១១៩,៤៦៧ គ.ម ក្នុងខេត្តគោលដៅចំនួន ០៦ រួមមាន៖ ខេត្តកំពង់ស្ពឺ ខេត្តកំពង់ឆ្នាំង ខេត្តកណ្តាល ខេត្តព្រៃវែង ខេត្តស្វាយរៀង និងខេត្តត្បូងឃ្មុំ បានបញ្ចប់ការអនុវត្តជាស្ថាពរកាលពីថ្ងៃទី១០ ខែតុលា ឆ្នាំ២០២២ ហើយបានរៀបចំពិធីសម្ពោធដាក់ឲ្យប្រើប្រាស់ជាផ្លូវការនៅថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ ២០២២។

### ២.៣.៦. គម្រោងពិពិធកម្មកសិកម្មកម្ពុជា

- បានប្រជុំសម្រេចជ្រើសរើសក្រុមហ៊ុនម៉ៅការ សម្រាប់ជួសជុលកែលម្អផ្លូវក្នុងខេត្តកំពង់ចាម ប្រវែង ២២,៥៣ គ.ម

- បានផ្ញើឯកសារលទ្ធកម្មសម្រាប់ជួសជុលកែលម្អផ្លូវកញ្ចប់ទី០២ ប្រវែង ៤៥ គ.ម ក្នុងខេត្តបាត់ដំបង ខេត្តកំពង់ឆ្នាំង ខេត្តព្រះវិហារ និងខេត្តស្ទឹងត្រែងទៅធនាគារពិភពលោកដើម្បីពិនិត្យនិងផ្តល់ការមិនយល់ទាស់(NOL)
- កំពុងរៀបចំឯកសារបច្ចេកទេសជួសជុលកែលម្អផ្លូវកញ្ចប់ទី០៣ ប្រវែង ៣៩គ.ម ក្នុងខេត្តកំពង់ស្ពឺ និងខេត្តព្រះវិហារ
- បានបន្តចុះស្រង់ទិន្នន័យផលប៉ះពាល់ផ្លូវដែលស្នើដោយសហគមន៍កសិកម្មចំនួន ០៤ ក្នុងខេត្តត្បូងឃ្មុំ និងខេត្តព្រះវិហារ ។

**២.៣.៧. គម្រោងនិរន្តរភាពតំបន់ទេសភាព និងទេសចរណ៍ធម្មជាតិកម្ពុជា**

- ទីតាំងភូមិទាំងអស់ នៃខេត្តគោលដៅចំនួន ០៣ គឺខេត្តកំពង់ស្ពឺ ខេត្តសៀមរាប និងខេត្តពោធិ៍សាត់ ត្រូវបានកំណត់នៅលើផែនទី ដើម្បីរៀបចំប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាត
- បញ្ចប់ដោយជោគជ័យការដេញថ្លៃសម្ភារៈធ្វើតេស្តគុណភាពផ្លូវ
- បញ្ចប់ពង្រាងលក្ខខណ្ឌ (TOR) ជ្រើសរើសទីប្រឹក្សាផ្នែកយេនឌ័រ
- បញ្ចប់លក្ខណៈវិនិច្ឆ័យនៃការជ្រើសរើសខ្សែផ្លូវអាទិភាពចំនួន ៣៣ ខ្សែ ដែលមានប្រវែងសរុប ១៥០ គ.ម នៃផ្លូវជនបទ ដែលមានសក្តានុពលក្នុងការវិនិយោគទាំងសហគមន៍ និងឯកជន ដោយមានការយល់ព្រមពីធនាគារពិភពលោក និងក្រសួងបរិស្ថាន
- សហការជាមួយក្រុមការងារក្រសួងបរិស្ថាន ដើម្បីធ្វើបច្ចុប្បន្នភាពផែនទីបង្ហាញខ្សែផ្លូវអាទិភាពដែលបានជ្រើសរើស និងប្រមូលទិន្នន័យផ្លូវជនបទ (ស្ថានភាពផ្លូវ និងរចនាសម្ព័ន្ធ)
- បានធ្វើការវាយតម្លៃនិងសិក្សាលម្អិត នៃតម្រូវការទឹកស្អាតនៅតាមខេត្តគោលដៅ ។

**២.៣.៨. គម្រោងកែលម្អផ្លូវជនបទជំហានទី៣ (RRIP III)**

- បាន និងកំពុងសាងសង់ ផ្លូវក្រាលកៅស៊ូពីរជាន់ក្រោមហិរញ្ញប្បទានរបស់ធនាគារ អភិវឌ្ឍន៍អាស៊ី (ADB) ចំនួន ២០ខ្សែ ប្រវែងសរុប ៣៤០,៨០ គ.ម នៅក្នុងខេត្តត្បូងឃ្មុំ ខេត្តកំពង់ចាម ខេត្តព្រៃវែង ខេត្តស្វាយរៀង និងខេត្តក្រចេះ សម្រេចបាន ៩២,៧០%
- បាន និងកំពុងសាងសង់ ផ្លូវក្រាលកៅស៊ូពីរជាន់ក្រោមហិរញ្ញប្បទានរបស់សាធារណរដ្ឋកូរ៉េ (EDCF) ចំនួន ៣៨ខ្សែ ប្រវែងសរុប ៣៦៥,២៤ គ.ម នៅខេត្តកំពង់ឆ្នាំង ខេត្តកំពង់ស្ពឺ ខេត្តតាកែវ ខេត្តកំពត និងខេត្តកណ្តាល សម្រេចបាន ៣៤,៤៣% ។

**២.៣.៩. កម្មវិធីអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធជនបទសម្រាប់កម្ពុជា (RID4CAM)**

កម្មវិធីអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធជនបទសម្រាប់កម្ពុជា(RID4CAM) គឺជាកម្មវិធីដែលទទួលបានហិរញ្ញប្បទានសហប្រតិបត្តិការពីធនាគារ KfW ទីភ្នាក់ងារបារាំងសម្រាប់ការអភិវឌ្ឍ (AFD) និងសហភាពអឺរ៉ុប (EU/AIF) សរុបចំនួន ៩៥,៤៣៥ លានអឺរ៉ូ ។ តាមរយៈនៃកម្មវិធី RID4CAM ផ្លូវក្រាលកៅស៊ូពីរជាន់ (DBST) និងផ្លូវបេតុង ប្រវែងសរុប ប្រមាណ ៥០០គីឡូម៉ែត្រ និងសំណង់សិល្បការមួយចំនួន នឹងត្រូវបានសាងសង់នៅក្នុងខេត្តគោលដៅ ចំនួន ០៥ រួមមាន ខេត្តព្រះវិហារ ខេត្តសៀមរាប

ខេត្តបាត់ដំបង ខេត្តកំពង់ធំ និងខេត្តកណ្តាល ដោយត្រូវអនុវត្តសម្រាប់រយៈពេល ០៥ឆ្នាំ ពីឆ្នាំ ២០២២ ដល់ឆ្នាំ ២០២៦ ។ គិតត្រឹមដំណាច់ខែឧសភា ឆ្នាំ ២០២៣ នេះ គម្រោងសម្រេចបាន៖

- បានបញ្ចប់ការជ្រើសរើស និងបានចុះកិច្ចព្រមព្រៀង ជាមួយក្រុមទីប្រឹក្សាបច្ចេកទេស ឈ្មោះ JV INROS LACKNER SE - GITEC IGIP GmbH
- បានបញ្ចប់នីតិវិធីធ្វើលទ្ធកម្មរថយន្តសម្រាប់អង្គភាពគ្រប់គ្រងកម្មវិធី
- កំពុងដំណើរការនីតិវិធីដេញថ្លៃសម្រាប់ការងារស្ថាបនាផ្លូវជនបទ ក្នុងខេត្តព្រះវិហារ និងខេត្តសៀមរាប ។

**២.៣.១០. គម្រោងអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធជនបទដែលធន់នឹងការប្រែប្រួលអាកាសធាតុ**

គម្រោងអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធជនបទដែលធន់នឹង ការប្រែប្រួលអាកាសធាតុជាគម្រោងដែលទទួលបានថវិកាពីរាជរដ្ឋាភិបាលកម្ពុជាចំនួន៦,១លានដុល្លារអាមេរិកនិងឥណទានរបស់សាធារណរដ្ឋកូរ៉េ ចំនួន ៥៧ លានដុល្លារអាមេរិក។ គម្រោងនឹងធ្វើការកែលម្អផ្លូវជនបទចំនួន ២៣ខ្សែ ពីផ្លូវក្រាលគ្រួសក្រហម មកជាផ្លូវបេតុង ដែលមានប្រវែងសរុប១៤៩,៦ គីឡូម៉ែត្រ នៅខេត្តគោលដៅចំនួន០៦គឺ ខេត្តត្បូងឃ្មុំ ខេត្តកំពង់ចាម ខេត្តព្រៃវែង ខេត្តកណ្តាល ខេត្តកំពង់ឆ្នាំង និងខេត្តកំពង់ស្ពឺ ។ គិតត្រឹមខែឧសភានេះ គម្រោងសម្រេចបានចុះកិច្ចសន្យាសាងសង់ជាមួយក្រុមហ៊ុន ILSUNG-KUMHO Join Venture និងត្រួតពិនិត្យដំណើរការអនុវត្តគម្រោងដោយសម្ព័ន្ធក្រុមហ៊ុនទីប្រឹក្សាបច្ចេកទេសកូរ៉េKCI-Seoyoung។

## ៣. ទិសដៅបន្តឆ្នាំ២០២៣

### ៣.១. បញ្ហាប្រឈម

- កង្វះឧបករណ៍ពិសោធន៍មួយចំនួន សម្រាប់ប្រើប្រាស់ទាំងក្នុងមន្ទីរពិសោធន៍ និងការងារពិសោធន៍នៅការដ្ឋានផ្ទាល់
- ការចូលរួមរបស់សហគមន៍ក្នុងការសម្រេចចិត្តលើការងារអភិវឌ្ឍន៍នៅមានកម្រិត ។

### ៣.២. ទិសដៅតាមអង្គភាព

- គ្រោងរៀបចំសិក្ខាសាលាពិគ្រោះយោបល់ ស្តីពីការអភិវឌ្ឍជនជាតិដើមភាគតិច និងសេចក្តីថ្លែងការណ៍គោលនយោបាយការពារ របស់ធនាគារអភិវឌ្ឍន៍អាស៊ី (ADB)
- រៀបចំផ្សព្វផ្សាយខ្លឹមសារ ស្តីពីអត្ថប្រយោជន៍ នៃការកំណត់អត្តសញ្ញាណ ជនជាតិដើមភាគតិចដល់ភូមិគោលដៅក្នុងខេត្តសៀមរាប និងខេត្តកំពង់ធំ
- រៀបចំឯកសារស្នើសុំទទួលស្គាល់អត្តសញ្ញាណសហគមន៍ ជនជាតិដើមភាគតិចជង ចំនួន 0៤ ភូមិ នៅខេត្តពោធិ៍សាត់
- បន្តកិច្ចសហប្រតិបត្តិការជាមួយដៃគូ និងអង្គការមិនមែនរដ្ឋាភិបាល
- បន្តចុះពិនិត្យការអនុវត្តផែនការសកម្មភាពរបស់អង្គការមិនមែនរដ្ឋាភិបាល
- បន្តចុះធ្វើអធិការកិច្ចជាប្រចាំទៅលើអង្គភាពក្រោមឱវាទក្រសួងអភិវឌ្ឍន៍ជនបទ
- បន្តរៀបចំ និងធ្វើបច្ចុប្បន្នភាពឯកសារសេចក្តីព្រាងគោលនយោបាយជាតិស្តីពីការអភិវឌ្ឍផ្លូវជនបទ

- បន្តការងារធ្វើបច្ចុប្បន្នភាពបញ្ជីសារពើភណ្ឌផ្លូវជនបទ
- បន្តពង្រឹងសមត្ថភាព និងចំណេះដឹងរបស់មន្ត្រីបច្ចេកទេសពិសោធន៍ក្នុងការអនុវត្តការងារពិសោធន៍ តាមរយៈការវាយតម្លៃ និងត្រួតពិនិត្យទៅលើគុណភាព រយៈពេល និងលទ្ធផលនៃការពិសោធន៍
- រៀបចំពង្រាងគោលការណ៍ណែនាំគតិយុត្ត និងបទដ្ឋានបច្ចេកទេសរបស់មន្ទីរពិសោធន៍
- ផ្សព្វផ្សាយផែនការសកម្មភាពជាតិ ស្តីពីការផ្គត់ផ្គង់ទឹកស្អាត និងអនាម័យជនបទ
- បន្តសហការសាកល្បងការផ្ទេរមុខងារអនាម័យទៅរដ្ឋបាលថ្នាក់ស្រុកទាំង១៥ ក្នុងខេត្តគោលដៅទាំង ០៣ គឺខេត្តត្បូងឃ្មុំ ខេត្តកំពង់ស្ពឺ និងខេត្តកំពង់ឆ្នាំង
- រៀបចំពិនិត្យសាឡើងវិញនូវផែនការសកម្មភាពជាតិជំហានទី១ (២០១៤-២០១៨) និងរៀបចំធ្វើផែនការសកម្មភាពជាតិជំហានទី២ ស្តីពីការផ្គត់ផ្គង់ទឹកស្អាត និងលើកកម្ពស់អនាម័យជនបទ (២០១៩-២០២៣)
- បន្តកិច្ចសហប្រតិបត្តិការជាមួយអង្គការដៃគូអភិវឌ្ឍន៍នានា និងស្ថាប័នពាក់ព័ន្ធ ដើម្បីបញ្ជូនមន្ត្រីឲ្យចូលរួមវគ្គបណ្តុះបណ្តាល សិក្ខាសាលា និងទស្សនកិច្ចសិក្សា ដើម្បីលើកកម្ពស់សមត្ថភាពមន្ត្រី
- ពង្រឹងការផ្តល់សេវាជូនប្រជាពលរដ្ឋដូចជាការងារតំណាងសាច់ប្រាក់ និងមិនមែនសាច់ប្រាក់ការបណ្តុះបណ្តាលបំនិនជីវិត ការរកទីផ្សារសម្រាប់ផលិតផលជនបទជាដើម
- ពង្រឹងកិច្ចសហប្រតិបត្តិការផ្នែកបច្ចេកទេសជាមួយវិស័យឯកជន និងដៃគូអភិវឌ្ឍន៍នានា
- រៀបចំកិច្ចប្រជុំជាមួយប្រធានមន្ទីរ អនុប្រធានមន្ទីរទទួលបន្ទុក និងប្រធានការិយាល័យអភិវឌ្ឍន៍ជនជាតិភាគតិចទាំង ១៥ ខេត្ត ចូលរួមកិច្ចប្រជុំពិភាក្សាការងារអភិវឌ្ឍន៍ជនជាតិដើមភាគតិច អំពីផែនការសកម្មភាព បញ្ហាប្រឈម និងទិសដៅការងារបន្ត
- រៀបចំឡើងវិញនូវនីតិវិធីចុះកំណត់អត្តសញ្ញាណជនជាតិដើមភាគតិច
- បន្តចុះវាយតម្លៃកំណត់អត្តសញ្ញាណជនជាតិដើមភាគតិចនិងសិក្សាស្រាវជ្រាវពីប្រពៃណីវប្បធម៌ ទំនៀមទម្លាប់ជនជាតិដើមភាគតិចនីមួយៗឱ្យបានច្បាស់លាស់
- បន្តតាមដាន និងជំរុញការទទួលស្គាល់អត្តសញ្ញាណពីអាជ្ញាធរមូលដ្ឋាន ភូមិ ឃុំ ស្រុក មន្ទីរអភិវឌ្ឍន៍ជនបទ និងរដ្ឋបាលខេត្ត ។

## ៤. សេចក្តីសន្និដ្ឋាន

ក្នុងខែឧសភា ឆ្នាំ២០២៣នេះ ការអនុវត្តផែនការសកម្មភាពការងារជំនាញពាក់ព័ន្ធនឹងហេដ្ឋារចនាសម្ព័ន្ធ ទឹកស្អាតជនបទ អនាម័យជនបទ ការបណ្តុះបណ្តាលជំនាញមូលដ្ឋាន ការអភិវឌ្ឍន៍ជនជាតិដើមភាគតិច ការអភិវឌ្ឍន៍សហគមន៍មានសកម្មភាពប្រសើរជាងខែមេសា។ ការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈរបស់ក្រសួងមានសកម្មភាពល្អប្រសើរ ។ ការងារសហប្រតិបត្តិការទំនាក់ទំនងអន្តរជាតិ និងគម្រោងដៃគូមានវឌ្ឍនភាពច្រើន។ តែទោះបីជាយ៉ាងនេះក្តីក៏គោលដៅទាំងពីររបស់ក្រសួងនៅតែបន្តទៅមុខរហូតដើម្បីឈានទៅសម្រេចបង្កើនជីវភាពរស់នៅសមរម្យ និងធានាសុខុមាលភាពជូនប្រជាជន

នៅជនបទ ចូលរួមអភិវឌ្ឍប្រទេសកម្ពុជា ក្នុងការសម្រេចគោលដៅឆ្ពោះទៅជាប្រទេសដែលមានប្រាក់ចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ២០៣០ ក្រោមការដឹកនាំប្រកបដោយគតិបណ្ឌិត **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** ។

**រដ្ឋមន្ត្រី**

បណ្ឌិតសភាចារ្យ **អ៊ុក រ៉ាប៊ុន**